# ក្រុមមេធាវីការពារក្ដី នួន ជា

## NUON CHEA DEFENCE TEAM

EXTRAORDINARY CHAMBERS IN THE COURTS OF CAMBODIA

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-2011, 14:56
CMS/CFO: Kauv Keoratanak

ភ្នំពេញថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

ចៅក្រម **និល ណុន**

ប្រធានអង្គជំនុំជម្រះសាលាដំបូង

បញ្ជូនតាមរយៈសំណុំរឿង

**កម្មវត្ថុ: សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright, Andrew Cayley, និង/ឬ Knut Rosandhaug**

លោកចៅក្រម **និល ណុន** ជាទីគោរព:

យើងខ្ញុំបានទទួល និងឃើញព័ត៌មានដែលបញ្ជាក់ថា កិច្ចប្រជុំសម្ងាត់បានកើតឡើងរវាងចៅក្រមម្នាក់របស់អង្គជំនុំជម្រះសាលាដំបូង គឺលោកស្រីចៅក្រម Dame Silvia Cartwright, និងសហព្រះរាជអាជ្ញាបរទេសលោក Andrew Cayley។ បើតាមព័ត៌មាន កិច្ចប្រជុំនេះក៏មានវត្តមានលោក Knut Rosandhaug អ្នកសម្របសម្រួល UNAKRT ផងដែរ។

នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Rosandhaug បញ្ជាក់ថា "ការប្រជុំទៀងទាត់រវាងចៅក្រម Cartwright ជាមួយសហព្រះរាជអាជ្ញាបរទេស និងអ្នកសម្របសម្រួល UNAKRT" ត្រូវបានចាប់ផ្ដើមមានឡើងតាំងពីខែ មេសា ឆ្នាំ ២០១១ មកម្ល៉េះ។ គាត់ថែមទាំងបញ្ជាក់ថា កិច្ចប្រជុំទាំងនេះគឺអំពី "កិច្ចការរដ្ឋបាល និងការរៀបចំ និងមិនមែនអំពីអង្គសេចក្ដីនៅក្នុងសំណុំរឿងនៅចំពោះមុខ អវតក ទេ"។ យើងខ្ញុំជាមេធាវី ឬ មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្ដី មិនដែលត្រូវបានប្រាប់ឲ្យដឹងអំពីជំនួបនោះទេ។

ក្នុងការឆ្លើយតបនឹងសារអេឡិចត្រូនិចនេះ លោក Michael Karnavas ជាសហមេធាវីបរទេសរបស់លោក អៀង សារី បានផ្ញើលិខិតមួយទៅ លោក Rosandhaug ដោយបញ្ជាក់ពីចំណាប់អារម្មណ៍ និងការភ្ញាក់ផ្អើលរបស់លោកអំពីកិច្ចប្រជុំសម្ងាត់នេះ។ ដើម្បីបន្ធូរបន្ថយការសង្ស័យសមហេតុផលនេះ លោក Karnavas បានស្នើឲ្យផ្ដល់នូវកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះ។ លិខិតត្រូវបានភ្ជាប់មកជាមួយនេះ។ នៅថ្ងៃដដែលយើងខ្ញុំបានចូលរួមជាមួយសំណើរបស់លោក Karnavas។ បើទោះនេះពិតជាបញ្ហាបន្ទាន់ក៏ដោយ ក៏យើងនៅមិនទាន់បានទទួលកំណត់ហេតុនៅឡើយទេ។

នៅក្នុងឱកាសពីរដង លើកទីមួយនៅថ្ងៃទី ០១ និងលើកទីពីរ នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០១១ យើងស្នើសុំការបញ្ជាក់ពីលោកស្រីចៅក្រម Cartwright ទាក់ទិននឹងជំនួបនេះ។ តែរហូតមកដល់ពេលនេះ យើងមិនបានទទួលចម្លើយអ្វីសោះ។

ដោយគិតពីការខិតចូលមកដល់កាត់តែជិតនូវសេចក្តីថ្លែងការបើកក្នុងសំណុំរឿង ០០២ យើងខ្ញុំសូមស្នើជាបន្ទាន់ដល់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យបង្ហាញ (១) បញ្ជីលម្អិតនូវរាល់ជំនួបទាំងអស់ដែលធ្វើឡើងរវាងលោកស្រីចៅក្រម Cartwright និង សមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា និង/ឬ លោក Rosandhaug (២) របៀបវារៈ និងកំណត់ហេតុនៃកិច្ចប្រជុំទាំងនោះ។ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះជំនួបបែបនោះ។

ដោយគោរព

| | |
|---|---|
| Michiel PESTMAN & Victor KOPPE | Andrew IANUZZI & Jasper PAUW |
| សហមេធាវី | ទីប្រឹក្សាច្បាប់ |

ចម្លងជូន: ចៅក្រមសាលាដំបូងទាំងអស់

Andrew CAYLEY, សហព្រះរាជអាជ្ញាបរទេស

Knut ROSANDHAUG, អ្នកសម្របសម្រួល UNAKRT

Nisha VALABHJI, មន្ត្រីទទួលបន្ទុកអង្គភាពគាំពារការការពារក្តី